**នៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 26-Jun-2015, 13:24
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅនឹងសំណើលើកទីមួយរបស់ នួន ជា ទាក់ទិននឹង បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១**

---

**ដាក់ដោយ÷**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ្រ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

**នៅចំពោះមុខ÷**

**អង្គជំនុំជម្រះតុលាការកំពូល៖**

**ចៅក្រម គង់ ស្រីម ប្រធាន**

**ចៅក្រម** A. KLONOWIECKA-MILART

**ចៅក្រម សោម សិរីវឌ្ឍ**

**ចៅក្រម** C.N. JAYASINGHE

**ចៅក្រម ម៉ុង មុន្នីចរិយា**

**ចៅក្រម យ៉ា ណារិន**

**ចៅក្រម** Florence Ndepele MWACHANDE -MUMBA

មុំច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

វ៉េន ពៅ

ទី ស្រ៊ុនណា

Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

<u>ផ្ញើជូន</u>÷

<u>ការិយាល័យសហព្រះរាជអាជ្ញា</u>៖

ជា លាង

Nicholas KOUMJIAN

<u>ជនជាប់ចោទ</u>៖

ខៀវ សំផន

នួន ជា

<u>សហមេធាវីការពារក្ដី</u>៖

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

<u>មេធាវីការពារប្រចាំការ</u>៖

ទូច វរល័ក្ស

Calvin SAUNDERS

<u>សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>៖

Olivier BAHOUGNE
Patrick BAUDOUIN
Beini Ye

## I. សេចក្ដីផ្ដើម

១. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមឆ្លើយតបទៅនឹងសំណើលើកទីបួនរបស់ នួន ជា សុំពិចារណាភស្តុតាងបន្ថែមដែលទាក់ទិននឹងបណ្ដឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ("សំណើលើកទីបួន")[1]។ សហមេធាវីនាំមុខកំហិតចម្លើយតបរបស់ខ្លួនចំពោះសំណើលើកទីបួន តែចំណុចនានាដែលពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណី និងសិទ្ធិរបស់ពួកគេប៉ុណ្ណោះ។

២. សហមេធាវីនាំមុខសូមលើកឡើងថា សំណើលើកទីបួនគួរតែត្រូវបានបដិសេធ ដោយផ្អែកលើមូលដ្ឋានថា សំណើនេះមិនស្របទៅនឹងលក្ខខណ្ឌនានានៃវិធាន ១០៨(៧) និង វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងទេ ហើយវាក៏មិនជួយក្នុងការបង្ហាញការពិតលើបណ្ដឹងសាទុក្ខដែរ។

## II. ប្រវត្តិនីតិវិធី

៣. មេធាវីការពារក្ដី នួន ជា បានដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រម[2] ក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៣[3] ដែល*ក្នុងចំណោមនោះ* ពួកគេជំទាស់ពីការធ្វើសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការកំណត់គោលដៅចំពោះទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ[4]។ នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ មេធាវីការពារក្ដី នួន ជា បានដាក់សំណើលើកទីបួន សុំឱ្យទទួលយកសក្ខីកម្មរបស់ ពេជ្រ ជឹម ក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ២៣ ដល់ទី២៤ ខែ មេសា ឆ្នាំ ២០១៥។ សាក្សី ពេជ្រ ជឹម ធ្លាប់បានផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃទី ១ ខែ កក្កដា

---

[1] សំណើលើកទីបួនរបស់ នួន ជា ស្នើសុំឱ្យពិចារណាលើភស្តុតាងបន្ថែម ទាក់ទិននឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ **F2/6** ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៥។

[2] សាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ **E313** ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ ("សាលក្រម")។

[3] បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ **F16** ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ("សារណាបណ្ដឹងសាទុក្ខ នួន ជា")។

[4] សារណាបណ្ដឹងសាទុក្ខ នួន ជា កថាខណ្ឌ ៥២៦ ដល់ ៥៩៩។

ឆ្នាំ ២០១៣[5]។

៤. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា អង្គជំនុំជម្រះនឹងមិន"បញ្ជូនការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌណាមួយពីសំណុំរឿង ០០២/០១ ទៅសំណុំរឿង ០០២/០២ ឡើយ"[6]។ ហេតុនេះ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចធ្វើសេចក្ដីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ ពាក់ព័ន្ធនឹងគោលនយោបាយក្នុងការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ជាក់លាក់ចំពោះបទចោទនានាក្នុងសំណុំរឿង ០០២/០២ ទោះបីត្រូវបានកំណត់ត្រឹមតែ "ការអនុវត្តនៅសហករណ៍នានានៅត្រាំកក់ ការដ្ឋានទំនប់ ១-មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់" ក៏ដោយ[7]។

៥. អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់នូវតម្រូវការចាំបាច់ ក្នុងការបញ្ចៀសនូវភាពមិនស៊ីសង្វាក់គ្នារវាងសវនាការដាច់ៗពីគ្នា ដោយកត់សម្គាល់ពីទំនាក់ទំនងទៅនឹងកិច្ចដំណើរការនីតិវិធីលើភ័ស្តុតាងដែលថា "ហានិភ័យណាមួយនៃភាពមិនស៊ីសង្វាក់គ្នារវាងដំណាក់កាលដាច់ៗពីគ្នានឹងមានកម្រិតទាប"[8]។

៦. ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានទទួលជាពិសេសនូវបទឧក្រិដ្ឋនានាស្ដីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ដែលភ្ជាប់ទៅនឹងគោលនយោបាយ "ពាក់ព័ន្ធនឹងគោលនយោបាយក្នុងការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋ កំណត់ត្រឹមតែការអនុវត្តនៅសហករណ៍នានានៅត្រាំកក់ ការដ្ឋានទំនប់ ១-មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរ

---

[5] *សូមមើល* ឯកសារ **E1/215.1** (ចុះថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣)។

[6] សេចក្ដីបញ្ជាក់បំភ្លឺអំពីផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ឯកសារ **E318** ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ទំព័រ ២ *ដកស្រង់ពី* សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ **E301/9/1/1/3** ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ ៨៥។

[7] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ **E301/9/1** ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ ៤៤ ("សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម")។

[8] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម កថាខណ្ឌ ២៩។

សន្តិសុខក្រាំងតាចាន់"[9]។ នៅក្នុងសំណុំរឿង ០០២/០១ សហជនជាប់ចោទមិនត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម នូវបទឧក្រិដ្ឋស្ដីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ពាក់ព័ន្ធនឹងការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃទេ[10]។

៧. ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានកំហិតការពិចារណារបស់ខ្លួនត្រឹមតែទៅលើគោលនយោបាយក្នុងការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ចំពោះបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់ថាពាក់ព័ន្ធនឹងការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃតែប៉ុណ្ណោះ[11]។ នៅក្នុងការធ្វើសេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមវិញ អង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណនៃគោលបំណងរួមដែលកើតចេញពី "គោលនយោបាយក្នុងការកំណត់គោលដៅផង និងគោលនយោបាយទីបីផង" ដែលជា "ការកម្ទេចខ្មាំង" ឬ "ការសម្លាប់ខ្មាំង""[12]។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានសំអាងលើសក្ខីកម្មរបស់ ពេជ្រ ជឹម ពីសំណុំរឿង ០០២/០១ ដែលពាក់ព័ន្ធនឹង "វគ្គរៀនសូត្ររយៈពេលមួយខែ នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៥ [...] ដែល នួន ជា បានបង្រៀនមនុស្សប្រហែល ៨០០ នាក់ អំពីប្រធានបទខ្មាំង" និងបានថ្លែងថា "ប្រសិនបើគ្មានការបង្រៀនរបស់ នួន ជា ទេនោះ "គេនឹងមិនដឹងអំពីរបៀបបែងចែកឲ្យដាច់រវាងខ្មាំង និងមិត្តឡើយ""[13]។

## III. ច្បាប់ជាធរមាន

៨. វិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យភាគីដាក់សំណើមួយទៅអង្គជំនុំជម្រះតុលាការកំពូលសុំដាក់ភស្តុតាងបន្ថែម ដែលមិនអាចរកបាននៅពេលសវនាការ និងអាចជាកត្តាសម្រេចក្នុងការចេញសេចក្ដីសម្រេចនៅពេលសវនាការ។ វិធាននេះអនុវត្ត "ទាំងលើអង្គហេតុដែលទើបរកបានថ្មីៗ

---

[9] *ដូចយោងខាងលើ* កថាខណ្ឌ ៩៥។

[10] *សូមមើល* សាលក្រម កថាខណ្ឌ ៨១២។

[11] *ដូចយោងខាងលើ* កថាខណ្ឌ ៨១៣។

[12] *ដូចយោងខាងលើ*។

[13] *ដូចយោងខាងលើ* កថាខណ្ឌ ៨១៨។

និងមធ្យោបាយថ្មីៗនៃភ័ស្តុតាងផង”[14]។ ភ័ស្តុតាងដែលស្នើឡើង បានស្នើសុំភ័ស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ ហេតុនេះត្រូវស្របទៅនឹងលក្ខខណ្ឌនានាដូចខាងក្រោម៖

ក. លក្ខខណ្ឌនៃភាពអាចទទួលយកបានតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

ខ. មិនអាចរកបាននៅពេលសវនាការ ទោះបីមានអនុវត្តការបំពេញការងារដោយយកចិត្តទុកដាក់ក៏ដោយ[15]។

គ. អាចជាកត្តាសម្រេចក្នុងការចេញសេចក្តីសម្រេចនៅសវនាការដោយបណ្តឹងសាទុក្ខ។ និង

ឃ. ពាក់ព័ន្ធនឹងការធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុដោយអង្គជំនុំជម្រះសាលាដំបូង។

៩. វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចបដិសេធផ្នែកនៃភ័ស្តុតាងដែលបានស្នើឡើងប្រសិនបើវា៖ មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង ច្បាប់មិនអនុញ្ញាត ឬ មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

---

[14] សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ ឯកសារ **F2/5** ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៥ កថាខណ្ឌ ១៥ (“សេចក្តីសម្រេចកោះហៅសាក្សីលើបណ្តឹងសាទុក្ខ”)។ សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើលើកទីមួយរបស់ នួន ជា សុំឱ្យទទួល និងពិចារណាទៅលើភ័ស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ **F2/4/3** ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ កថាខណ្ឌ ១៥។

[15] លក្ខខណ្ឌនៃ “ការអនុវត្តការងារដោយយកចិត្តទុកដាក់” មានប្រភពពីយុត្តាធិការនៅកម្រិតអន្តរជាតិ ដើម្បីបញ្ចៀសយុត្តិសាស្ត្របណ្តឹងវិវាទដែលរំខាន និង គ្មានប្រសិទ្ធផល។ *សូមមើលបន្ថែម* សេចក្តីសម្រេចកោះហៅសាក្សីលើបណ្តឹងសាទុក្ខ ជើងទំព័រ ៤៩ ដល់ ៥០ *ដកស្រង់ពី ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Lubanga សំណុំរឿងលេខ ICC-01/04-01/06 A 5 សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងការផ្តន្ទាទោសរបស់គាត់ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤ (“សាលដីកាក្នុង *រឿងក្តី Lubanga*”) កថាខណ្ឌ ៥០ ដោយសង្ខេបច្បាប់យុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR លើចំណុចនេះ)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Nahimana និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-99-52-A សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងសាទុក្ខ Jean-Bosco Barayagwiza សុំការអនុញ្ញាតដាក់បង្ហាញភ័ស្តុតាងបន្ថែម អនុលោមតាមវិធាន ១១៥ នៃវិធាននីតិវិធីនិងភ័ស្តុតាង ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Zoran Kupreškić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-95-16-A សេចក្តីសម្រេចលើញត្តិរបស់ Drago Josipović, Zoran Kupreškić និង Vlatko Kupreškić សុំឱ្យទទួលយកភ័ស្តុតាងបន្ថែម អនុលោមតាមវិធាន ១១៥ និងសុំសេចក្តីជូនដំណឹងរបស់តុលាការដែលត្រូវបានដាក់អនុលោមតាមវិធាន ៩៤(ខ) ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០០១ កថាខណ្ឌ ៣។

១០. អនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះតុលាការកំពូលអាច "កោះហៅភ័ស្តុតាងថ្មី" ដើម្បីធ្វើការសម្រេចលើបណ្តឹងសាទុក្ខ*ទៅតាមគំនិតផ្តួចផ្តើម*របស់ខ្លួន នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ ដោយត្រូវពិចារណាទៅលើកាលៈទេសៈជាក់លាក់នៃរឿងក្តី[16]។ បើតាមខ្លឹមសារនៃវិធាន ១០៤*ស្ទួន* នៃវិធានផ្ទៃក្នុង[17] អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាដល់អំណាចនេះក្នុងការកោះហៅ "ភ័ស្តុតាងថ្មី" ដែលស្របទៅនឹងលក្ខខណ្ឌនានានៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ ហេតុនេះ ក្នុងការអនុវត្តឆន្ទានុសិទ្ធិនេះ អង្គជំនុំជម្រះនឹងពិចារណាថាតើភ័ស្តុតាងនេះ "នឹងជួយក្នុងការស្វែងរកការពិត" ដែរ ឬយ៉ាងណា[18]។

១១. ភ័ស្តុតាងដែលបានស្នើសុំឱ្យទទួលយកតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ត្រូវតែបានបង្ហាញថាមិនអាចរកបានទេ*នៅពេលសវនាការ*។ អនុលោមតាមវិធាននេះ ភាគីស្នើសុំត្រូវបង្ហាញថា ភ័ស្តុតាងបន្ថែមអាចជាកត្តាសម្រេចក្នុងការចេញសេចក្តីសម្រេចនៅពេលសវនាការ ហើយសំណើត្រូវកំណត់អំពីសេចក្តីសន្និដ្ឋានជាក់លាក់ដែលត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង ទៅតាមគោលដៅនៃភ័ស្តុតាងបន្ថែមនេះ។ ចំណែកភ័ស្តុតាងដែលបានស្នើសុំឱ្យទទួលយកតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ត្រូវតែមិនអាចរកបាន*នៅមុនពេលបើកសវនាការ*។ នីតិវិធីសម្រាប់ការទទួលយកភ័ស្តុតាងថ្មី និងភ័ស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខត្រូវស្របតាមលក្ខខណ្ឌនានានៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

## IV. ការពិភាក្សា

១២. សិទ្ធិក្នុងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះតុលាការកំពូលរួចមកហើយ[19]។ អនុលោមតាមយុត្តិសាស្ត្រនោះ សហមេធាវីនាំមុខសូមឆ្លើយតបទៅ

---

[16] សេចក្តីសម្រេចកោះហៅសាក្សីលើបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧។

[17] វិធាន ១០៤*ស្ទួន* នៃវិធានផ្ទៃក្នុង៖ "រាល់វិធានដែលត្រូវអនុវត្តនៅអង្គជំនុំជម្រះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះអង្គជំនុំជម្រះតុលាការកំពូលក្នុងករណីសមស្រប ប្រសិនបើគ្មានបទប្បញ្ញត្តិដោយឡែកណាមួយនោះទេ"។

[18] សេចក្តីសម្រេចកោះហៅសាក្សីលើបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧។

[19] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F10/2** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១៥ ដល់ ១៦។ *សូមមើលបន្ថែម* ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo* សំណុំរឿងលេខ ICC-01/04-01/06-2958 ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១០ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ* ស្ថានភាពនៅសាធារណរដ្ឋប្រជា

នឹងសំណើក្នុងកម្រិតដែលថា សំណើនោះប៉ះពាល់ដល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ សហមេធាវីនាំមុខសូមលើកជាទឡ្ហីករណ៍នៅក្នុងផ្នែក ឃ ខាងក្រោមថា សំណើលើកទីបួន ផ្ទុយនឹងភាពចាំបាច់នៃសវនាការឆាប់រហ័ស និង តុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់ រួមទាំងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។

### ក. ការធ្វើសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ស្ដីពីការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ

១៣. សហមេធាវីនាំមុខសូមមិនឆ្លើយតបជាក់លាក់ទៅលើទឡ្ហីករណ៍នានារបស់មេធាវីការពារ នួន ជា ទៅលើខ្លឹមសារនានាដែលទាក់ទិននឹងតម្លៃនៃភ័ស្ដុតាងរបស់ ពេជ្រ ជឹម ពាក់ព័ន្ធនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្ដកម្ពុជាដើម្បីកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងរបៀបនៃអំណានចំពោះភ័ស្ដុតាងនោះជាមួយនឹងភ័ស្ដុតាងផ្សេងទៀតនៅក្នុងកំណត់ហេតុ[20]។ សហមេធាវីនាំមុខសូមលើកឡើងថា ការបញ្ជាក់ទាំងនេះសំដៅដល់អំណះអំណាងបន្ថែមដែលជំនួសមូលដ្ឋាននានានៃបណ្ដឹងសាទុក្ខដែលបានលើកឡើងនៅក្នុងសារណាបណ្ដឹងសាទុក្ខរបស់ នួន ជា។ ហេតុនេះ ចម្លើយតបនេះកំហិតត្រឹមតែសំណើសុំឲ្យទទួលយកប្រតិចារឹករបស់ ពេជ្រ ជឹម ក្នុងសំណុំរឿង ០០២/០២ ប៉ុណ្ណោះ។

### ខ. សំណើលើកទីបួនមិនបំពេញទៅតាមលក្ខខណ្ឌនានានៃវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងទេ

១៤. សហមេធាវីនាំមុខសូមលើកឡើងថា សំណើលើកទីបួន មិនស្របទៅនឹងបទដ្ឋានតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងដែលលក្ខខណ្ឌនៃ "ការបំពេញការងារដោយយកចិត្តទុកដាក់" ក្នុងការស្វែងរក

ធិបតេយ្យកុងហ្គោ នៅក្នុង *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo* សំណុំរឿងលេខ ICC-01/04-01/06-2951 ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៥ (ភាសាអង់គ្លេស)៖ "អនុលោមតាមវិធាន ៩១(១) នៃវិធាននីតិវិធី និងភ័ស្ដុតាង និងពាក់ព័ន្ធនឹងវិធាន ៩១(២), ៩២(៥) និង (៦) នៃវិធាននីតិវិធី និងភ័ស្ដុតាង អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ជនរងគ្រោះអាចចូលរួមក្នុងបណ្ដឹងសាទុក្ខទាំងនេះបាន ទៅតាមលក្ខណៈដូចតទៅ៖ អ្នកតំណាងផ្លូវច្បាប់របស់ជនរងគ្រោះ VOI និង V02 អាចបង្ហាញមតិនិងកង្វល់របស់ជនរងគ្រោះ ពាក់ព័ន្ធនឹងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងបញ្ហានេះលើបណ្ដឹងសាទុក្ខ ដោយការដាក់សេចក្ដីសន្និដ្ឋានរួមទៅលើឯកសារបីដើម្បីគាំទ្រដល់បណ្ដឹងសាទុក្ខ"។

[20] សំណើលើកទីបួន កថាខណ្ឌ ១២ ដល់ ១៨។

ថាតើផ្នែកនៃភ័ស្តុតាងមិនអាចរកបាននៅឯសវនាការមិនត្រូវបានបំពេញ ឬយ៉ាងណា[21]។

១៥. ជាគោលការណ៍ សហមេធាវីនាំមុខមិនជំទាស់ទៅនឹងការស្នើសុំឱ្យទទួលយកភ័ស្តុតាងបន្ថែមលើបណ្ដឹងសាទុក្ខដែលបានកើតឡើងពីកិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការក្នុងសំណុំរឿង ០០៣ និង ០០៤ នៅ អ.វ.ត.ក និង ភ័ស្តុតាងណាផ្សេងទៀតដែលមិនអាចរកបាន និង ដែលឱកាសនៃការសួរដេញដោលភ័ស្តុតាងបែបនេះមិនមានក្នុងអំឡុងពេលនៃសំណុំរឿង ០០២/០១ ទេ។

១៦. ទោះជាយ៉ាងណា សហមេធាវីនាំមុខសូមលើកឡើងថា មានឱកាសក្នុងការសួរដេញដោល ពេជ្រ ជឹម ក្នុងសំណុំរឿង ០០២។ នៅមុនពេលសក្ខីកម្មរបស់ ពេជ្រ ជឹម សហព្រះរាជអាជ្ញារងបានថ្លែងនៅក្នុងសវនាការជាសាធារណៈថា សាក្សីបន្ទាប់គឺជា "លេខាស្រុកត្រាំកក់ [...]។ សាក្សីនេះត្រូវបានសហចៅក្រមស៊ើបទៅសម្ភាសចំនួនប្រាំដងមកហើយ ហើយ [បាន] ផ្ដល់ [...] ព័ត៌មានសំខាន់ៗបំផុតទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ *[sic]*។ សាក្សីរូបនេះ [បាន] រៀបរាប់ [...] ទទួលការណែនាំពីគណៈកម្មាធិការតំបន់ឲ្យទទួលយកប្រជាជនដែលជម្លៀស គាត់ [បាន] រៀបរាប់ [...] ពីរបៀប និងពេលដែលប្រជាជនដែលជម្លៀសធ្វើដំណើរតាមផ្លូវចេញពីទីក្រុងភ្នំពេញទៅត្រាំកក់ថា ទាហាន លន់ នល់ ត្រូវបានដកចេញ ហើយថា អ្នកដែលទៅដល់នៅត្រាំកក់ គឺមានតែប្រពន្ធៗរបស់ទាហានទាំងអស់នោះតែប៉ុណ្ណោះ គឺពួកទាហាន លន់ នល់ គឺត្រូវបានដកចេញទាំងអស់"[22]។

១៧. ក្នុងអំឡុងពេលសួរដេញដោលរូបគាត់ក្នុងសំណុំរឿង ០០២/០១ សាក្សីត្រូវបានសួរសំណួរជាច្រើនដែលពាក់ព័ន្ធនឹងនិយមន័យនៃពាក្យថា "ខ្មាំង"[23] "ការកម្ទេច"[24] តួនាទីរបស់ តាម៉ុក[25] និងវគ្គរៀនសូត្រជាមួយ នួន ជា នៅក្រុងភ្នំពេញ[26]។ មេធាវីការពារក្ដី នួន ជា បានសួរដេញដោលរូបគាត់យ៉ាងយូរ តែបានប្រើឱកាសដេញដោលនូវទិដ្ឋភាពនានានៃសក្ខីកម្មរបស់គាត់ដែលពាក់ព័ន្ធនឹង

---

[21] *សូមមើល* ជើងទំព័រ ១៤ *ខាងលើ*។

[22] ឯកសារ **E1/114.1** (ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២) ទំព័រ ១៩ ដល់ ២០ (ភាសាអង់គ្លេស)។

[23] *សូមមើល* ឯកសារ **E1/215.1** (ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៣) ទំព័រ ១០ ដល់ ១១, ១៩ ដល់ ២០, ៣៦ ដល់ ៣៧, ៤៩ ដល់ ៥០, ៦១ ដល់ ៦៣ (ភាសាអង់គ្លេស)។

[24] *សូមមើល ដូចយោងខាងលើ* ទំព័រ ៣៧ ដល់ ៣៨ (ភាសាអង់គ្លេស)។

[25] *សូមមើល ដូចយោងខាងលើ* ទំព័រ ១៩ ដល់ ២០, ៣៥ ដល់ ៣៦, ៤៦ (ភាសាអង់គ្លេស)។

[26] *សូមមើល ដូចយោងខាងលើ* ទំព័រ ៣៨ ដល់ ៤១ (ភាសាអង់គ្លេស)។

"ខ្មាំងខាងក្រៅ" "ការបាត់ខ្លួន" ទាហានពីឃោធា លន់ នល់ និងវគ្គរៀនសូត្ររបស់ នួន ជា[27]។ ជាងនេះទៀត សំណួរជាសក្ខីពលនានាដែលជុំវិញអត្ថន័យសមទំនងនៃពាក្យថា "កម្ចាត់" ដែលមេធាវីការពារក្តី នួន ជា ដឹងយ៉ាងច្បាស់មុនពេលសួរដេញដោល ពេជ្រ ជឹម[28]។ សំណួរទាំងនេះក៏ត្រូវបានយកមកប្រើសម្រាប់សួរដេញដោល Stephen Heder ផងដែរ[29]។

១៨. ជាងនេះទៀត ពេជ្រ ជឹម ត្រូវបានស្នើដោយមេធាវីការពារក្តី នួន ជា នៅក្នុងបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានធ្វើបច្ចុប្បន្នភាពរបស់ខ្លួន ដោយថ្លែងថា គាត់អាច "ផ្តល់ព័ត៌មានផ្ទៃក្នុងអំពីស្ថានភាពនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ជាពិសេសរចនាសម្ព័ន្ធចាត់តាំងរបស់បក្សកុម្មុយនីស្ត និងរចនាសម្ព័ន្ធចាត់តាំងជាជម្រើសផ្សេងទៀតនៅក្នុងខ្មែរក្រហម"[30]។ ទោះជាយ៉ាងណា ក្នុងអំឡុងពេលសក្ខីកម្មរបស់គាត់នៅខែ កក្កដា ឆ្នាំ ២០១៣ មេធាវីការពារក្តី នួន ជា មិនបានសួរដេញដោលពេញលេញទៅលើសក្ខីកម្មទាំងនេះទេ ដែលស្ថិតក្នុងវិសាលភាពជាក់លាក់នៃសំណុំរឿង ០០២/០១។ សហមេធាវីនាំមុខសូមលើកឡើងថា ការសម្រេចចិត្តរបស់មេធាវីការពារក្តី នួន ជា ក្នុងការមិនដេញដោលលម្អិតទៅលើភស្តុតាងដែលពាក់ព័ន្ធនឹងកាលៈទេសៈនានា និងខ្លឹមសារនៃវគ្គរៀនសូត្រដែលរៀបចំដោយ នួន ជា មិនមែនមិនអាចរកបាននៅពេលសវនាការ សម្រាប់គោលបំណងនៃវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុងទេ[31]។

១៩. ជាងនេះទៀត សហមេធាវីនាំមុខសូមលើកឡើងថា សំណើលើកទីបួនលើកជាទឡ្ហីករណ៍ថា ផ្នែកនេះនៃភស្តុតាងបន្ថែមនឹង "បានគាំទ្រដល់ទឡ្ហីករណ៍យ៉ាងសំខាន់របស់មេធាវីការពារក្តី ដែលត្រូវបានច្រានចោលដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសាលក្រម ហើយជាចំណុចស្នូលនៃការ

---

[27] *សូមមើល ដូចយោងខាងលើ* ទំព័រ ៥៥ ដល់ ៨០ (ភាសាអង់គ្លេស)។ សូមមើលជាពិសេស *ដូចយោងខាងលើ* ទំព័រ ៦២ ដល់ ៦៧, ៧០ ដល់ ៧៥ (ភាសាអង់គ្លេស)។

[28] *សូមមើល* ឯកសារ **E1/135.1** (ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២) ទំព័រ ៤៦ ដល់ ៤៧ (ភាសាអង់គ្លេស)។

[29] *សូមមើល* ឯកសារ **E1/224.1** (ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៣) ទំព័រ ១០៣ ដល់ ១០៥ (ភាសាអង់គ្លេស)។

[30] សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាព ស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឡើង ឧបសម្ព័ន្ធ "សាក្សី" ឯកសារ **E93/4.3** ទំព័រ ៤១ លេខរៀង ៤៤៦។

[31] *សូមមើលបន្ថែម រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-A សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងសាទុក្ខដែលស្នើសុំពន្យារពេលកំណត់ និងសុំឱ្យទទួលយកភស្តុតាងបន្ថែម ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៤៧ (ភាសាអង់គ្លេស)។

វាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា"[32] តែមិនបានបង្ហាញពីរបៀបដែលសំណើនេះជំទាស់ទៅនឹងភស្តុតាង*ដែលអង្គជំនុំជម្រះសាលាដំបូងយកមកសំអាង*នៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១ ទេ[33]។ សំណើនេះក៏មិនបានបង្ហាញពីរបៀបដែលការមិនបញ្ចូលផ្នែកនេះនៃភស្តុតាងបន្ថែមនឹង "នាំឲ្យមានភាពអយុត្តិធម៌ ប្រសិនបើវាមិនត្រូវបានទទួលយកនៅពេលសវនាការ វា*នឹង*មានផលប៉ះពាល់ទៅលើសាលក្រម" ទេ[34]។

២០. ដោយសារសំអាងហេតុទាំងនេះ សហមេធាវីនាំមុខសូមលើកឡើងថា សំណើលើកទីបួនមិនបំពេញតាមបទដ្ឋានដែលបានកំណត់ក្នុងវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង ហេតុនេះសំណើនេះគួរត្រូវបដិសេធ។

**គ. សំណើលើកទីបួនមិនបំពេញតាមលក្ខខណ្ឌនានានៃវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងទេ**

២១. សំណើលើកទីបួនបានធ្វើសំណើម្យ៉ាងទៀតស្នើសុំឲ្យទទួលយកប្រតិចារឹកនានារបស់ ពេជ្រ ជឹម អនុលោមតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង[35]។ សហមេធាវីនាំមុខសូមលើកឡើងថា សំណើលើកទីបួនមិនស្របទៅនឹងបទដ្ឋានសម្រាប់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីអនុវត្តឆន្ទានុសិទ្ធិ

---

[32] សំណើលើកទីបួន កថាខណ្ឌ ២១។

[33] សូមមើល *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-88-A សេចក្តីសម្រេចលើញត្តិរបស់ Vujadin Popović ដែលស្នើសុំឲ្យទទួលយកភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ អនុលោមតាមវិធាន ១១៥ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ កថាខណ្ឌ ៣៩ (ភាសាអង់គ្លេស) បានសំអាងទៅលើ សាលដីកាក្នុង*រឿងក្តី Lubanga* កថាខណ្ឌ ៥០ (ភាសាអង់គ្លេស) និងនៅក្នុង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krajišnik* សំណុំរឿងលេខ IT-00-39-A សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងសាទុក្ខ Momčilo Krajišnik ដែលសុំដាក់បង្ហាញភស្តុតាងបន្ថែម ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ៥ (ភាសាអង់គ្លេស) (គូសបញ្ជាក់បន្ថែម)។

[34] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-88-A សេចក្តីសម្រេចលើញត្តិរបស់ Vujadin Popović ដែលស្នើសុំឲ្យទទួលយកភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ អនុលោមតាមវិធាន ១១៥ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ កថាខណ្ឌ ១០ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ* សាលដីកាក្នុង*រឿងក្តី Lubanga* កថាខណ្ឌ ៥៩ (ភាសាអង់គ្លេស)។ ទោះបី បទបញ្ជា ៦២ នៃបទបញ្ជារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") មិនតម្រូវឲ្យអ្នកដាក់ពាក្យសុំបង្ហាញពីផលប៉ះពាល់នៃភស្តុតាងបន្ថែមក៏ដោយ តែក្រៅពីបង្ហាញពីភាពជាប់ពាក់ព័ន្ធរបស់វាទៅនឹងមូលដ្ឋានណាមួយនៃបណ្តឹងសាទុក្ខនោះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC បានផ្តល់ការសង្កេតថា ជាការចាំបាច់ក្នុងការលើកឡើងនូវលក្ខខណ្ឌវិនិច្ឆ័យមួយដែលថា ភស្តុតាងបន្ថែមអាចនាំឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសាលក្រមមួយផ្សេង ទាំងស្រុង ឬមួយផ្នែក។

[35] សំណើលើកទីបួន កថាខណ្ឌ ២២ ដល់ ២៣។

របស់ខ្លួនក្នុងការយកមកប្រើវិធាន ១០៤(១) នៃវិធានផ្ទៃក្នុងទេ។

២២. សំណើលើកទីបួនអះអាងថា "បើទោះបីជាសក្ខីកម្មរបស់ ពេជ្រ ជឹម មួយផ្នែកឬទាំងស្រុង ហាក់ដូចជាមិនអាចបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ១០៨(៧) និង ៨៧(៣) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏សក្ខីកម្មនេះនៅតែអាចទទួលយកបានតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ដើម្បីផលប្រយោជន៍យុត្តិធម៌" ហើយថា វាផ្តល់ "ការគាំទ្រយ៉ាងសំខាន់ចំពោះភស្តុតាងដោះបន្ទុក ដែលមេធាវីការពារក្តីបានដកស្រង់" ហើយហេតុនេះ វាជា "ការចាំបាច់" លើបណ្តឹងសាទុក្ខ[36]។

២៣. ដោយកត់សម្គាល់ពីការណ៍ដែលថា អង្គជំនុំជម្រះតុលាការកំពូលធ្លាប់បានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនអនុលោមតាមវិធាន ១០៤(១) ដោយផ្អែកលើ*គំនិតផ្តួចផ្តើមរបស់ខ្លួន*[37] សហមេធាវីនាំមុខសូមលើកឡើងថា សំណើលើកទីបួនគ្រាន់តែយោងទៅលើបញ្ញត្តិនេះ តែមិនមានសេចក្តីសន្និដ្ឋានដែលមានសំអាងហេតុដែលបង្ហាញពីរបៀបបង្ហាញថា លក្ខខណ្ឌនានាតាមវិធាន ៨៧(៣) ដល់ (៤) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញនៅក្នុងករណីពិសេសនេះ អនុលោមតាមវិធាន ១០៤*ស្ទួន* នៃវិធានផ្ទៃក្នុងទេ។

២៤. មេធាវីការពារក្តី នួន ជា ស្វែងរកការគាំទ្រពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការកោះហៅសាក្សីលើបណ្តឹងសាទុក្ខ ដោយដកស្រង់ និងទទួលយកសាលដីកាក្នុង*រឿងក្តី Lubanga* ក្នុងការអះអាងថា អង្គជំនុំជម្រះលើបណ្តឹងសាទុក្ខអាចទទួលយកភស្តុតាងលើបណ្តឹងសាទុក្ខ ទោះបីការធ្វើសេចក្តីសន្និដ្ឋានជាអវិជ្ជមានទៅលើលក្ខខណ្ឌវិនិច្ឆ័យមួយឬច្រើនដែលគ្រប់គ្រងភាពអាចទទួលយកបាននៃភស្តុតាងលើបណ្តឹងសាទុក្ខក៏ដោយ[38]។

២៥. សហមេធាវីនាំមុខសូមឆ្លើយតបថា សំណើលើកទីបួនមិនយកចិត្តទុកដាក់ថា ការសម្រេចនៅក្នុងសាលដីកាក្នុង*រឿងក្តី Lubanga* ត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃការព្រួយបារម្ភជាពិសេសដែលថា ដំណាក់កាលបណ្តឹងសាទុក្ខនៅតុលាការ ICC ចាំបាច់ ជាដំណាក់កាលដែលមាន "លក្ខណៈកែ

---

[36] *ដូចយោងខាងលើ* កថាខណ្ឌ ២៣។

[37] សេចក្តីសម្រេចកោះហៅសាក្សីលើបណ្តឹងសាទុក្ខ កថាខណ្ឌ ១៧, ២៦។

[38] សំណើលើកទីបួន កថាខណ្ឌ ២២ *យោងទៅដល់* សេចក្តីសម្រេចកោះហៅសាក្សីលើបណ្តឹងសាទុក្ខ ជើងទំព័រ ៥១។

តម្រូវ” នោះទេ[39]។ នៅ អ.វ.ត.ក ទោះបី អង្គជំនុំជម្រះតុលាការកំពូលពិតជាវាយតម្លៃពីភាពត្រឹមត្រូវនៃការធ្វើសេចក្តីសន្និដ្ឋានក៏ដោយ តែវាកំហិតត្រឹមថា ការវាយតម្លៃចំពោះការពិនិត្យទៅលើបញ្ហាថាតើអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញនូវខ្លឹមសារនៃបទដ្ឋានផ្លូវច្បាប់ជាធរមានទៅលើប្រភពច្បាប់ដែលសមស្រប និង វិធាននៃការបកស្រាយដែលត្រូវបានយកមកអនុវត្ត ពាក់ព័ន្ធនឹងប្រភពច្បាប់ទាំងនោះ ឬយ៉ាងណា[40]។

២៦. សហមេធាវីនាំមុខសូមលើកឡើងថា ការសម្រេចជាពិសេសដោយអង្គជំនុំជម្រះលើបណ្តឹងសាទុក្ខនៅក្នុងរឿងក្តី *Lubanga* មិនត្រូវបានយល់ថាជាដំណោះស្រាយធម្មតាលើបណ្តឹងសាទុក្ខ សម្រាប់

---

[39] *សូមមើល* សាលដីកាក្នុង*រឿងក្តី* Lubanga កថាខណ្ឌ ១៦ (ភាសាអង់គ្លេស) *ប្រៀបធៀប រឿងក្តី ព្រះរាជអាជ្ញា តទល់នឹង ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជតក សាលដីកា ឯកសារ F28 ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១១ ដល់ ១៧។ *សូមមើលបន្ថែម* សាលដីកាក្នុង*រឿងក្តី* Lubanga កថាខណ្ឌ ៥៦ (ភាសាអង់គ្លេស)៖ “អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខមានភាពខុសប្លែកជាច្រើន ទាំងក្នុងលក្ខណៈនិងគោលបំណង ពីកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលមុនសវនាការ និង ដំណាក់កាលសវនាការ។ ជាការសំខាន់ កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនៅតុលាការគឺមានលក្ខណៈកែតម្រូវ ដែលក្នុងចំណោមនោះ សន្និដ្ឋានជាមតិយោបល់ទៅតាមបទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខ ដូចបានលើកឡើងខាងលើ។ ពាក់ព័ន្ធនឹងកំហុសលើអង្គហេតុដែលបានលើកឡើង បទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខមានភាពខុសប្លែកពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយការពិនិត្យលើបណ្តឹងសាទុក្ខត្រូវបានកំហិតជាសំខាន់ត្រឹមតែ ថាតើការធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈមិនសមហេតុផល ឬយ៉ាងណា តែមិនមែនជាការវាយតម្លៃសារជាថ្មីទេ។ ស្រដៀងគ្នាដែរ មាត្រា ៨៣(២) នៃលក្ខន្តិកៈកំហិតវិសាលភាពនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ ដោយតម្រូវថា កំហុសលើអង្គហេតុ ឬអង្គច្បាប់ផ្នែកនីតិវិធីត្រូវតែមានឥទ្ធិពលជាដុំកំភួនទៅលើការផ្តន្ទាទោស ឬ សេចក្តីសម្រេចក្នុងការដាក់ទោស ឬថា ភាពអយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីមានសក្តានុពលក្នុងការធ្វើឱ្យសេចក្តីសម្រេចទាំងនោះមិនអាចជឿជាក់បាន។ ក្នុងករណីនេះ កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខមិនពាក់ព័ន្ធនឹងការកែតម្រូវកំហុសទាំងអស់ដែលអាចកើតមាននៅពេលសវនាការទេ តែផ្ទុយទៅវិញលុះត្រាតែកំហុសដែលបានបង្ហាញទាំងនោះប៉ះពាល់ជាដុំកំភួនទៅលើសេចក្តីសម្រេចដែលពាក់ព័ន្ធ”។ អនុលោមតាមមាត្រា ៨១(១)(ខ) នៃលក្ខន្តិកៈតុលាការ ICC នៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចផ្តន្ទាទោស ទណ្ឌិតអាចលើកឡើងនូវ (i) កំហុសផ្នែកនីតិវិធី (ii) កំហុសលើអង្គហេតុ ឬ (iii) កំហុសលើអង្គច្បាប់ រួមទាំង (iv) “មូលដ្ឋានផ្សេងទៀតដែលមានឥទ្ធិពលលើភាពយុត្តិធម៌ ឬ ភាពអាចជឿជាក់បាននៃកិច្ចដំណើរការនីតិវិធី ឬ សេចក្តីសម្រេច”។ មាត្រា ៨៣(២) នៃលក្ខន្តិកៈតុលាការ ICC ក៏ចែងដែលថា អង្គជំនុំជម្រះតុលាការកំពូលត្រឹមតែអាចជ្រៀតជ្រែកទៅលើសេចក្តីសម្រេចផ្តន្ទាទោសបាន ប្រសិនបើកំហុសលើអង្គហេតុ ឬអង្គច្បាប់ ឬ កំហុសផ្នែកនីតិវិធី “ដែលបានប៉ះពាល់ជាដុំកំភួន” ទៅលើសេចក្តីសម្រេចនោះតែប៉ុណ្ណោះ ហើយពាក់ព័ន្ធនឹងការចោទប្រកាន់ពីភាពមិនយុត្តិធម៌ គឺថា ភាពមិនយុត្តិធម៌នេះ “បានប៉ះពាល់ទៅដល់ភាពអាចជឿជាក់បាននៃសេចក្តីសម្រេចនោះ”។

[40] សាលដីកាក្នុង*រឿងក្តី ឌុច* កថាខណ្ឌ ១៤។

ការទទួលយកជាភ័ស្តុតាងបែបធម្មតា ដែលត្រូវបានយកមកពិចារណាព្រមៗគ្នាដោយអង្គជំនុំជម្រះសាលាដំបូងនោះទេ។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC បានទទួលស្គាល់ថា ជាទូទៅអង្គជំនុំជម្រះ *មិនទទួលយកភ័ស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខទេ* ល្គឹកណាតែមានសំអាងហេតុដែលអាចជឿជាក់បានពីមូលហេតុដែលភ័ស្តុតាងបែបនេះមិនត្រូវបានដាក់បង្ហាញនៅពេលសវនាការ[41] ដោយអនុម័តយកបទដ្ឋានមួយដែលតឹងរ៉ឹងជាងមុខ ដែលដកស្រង់ចេញពី "គោលការណ៍ដែលថាភ័ស្តុតាងគួរតែដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឲ្យបានច្រើនតាមតែអាចធ្វើទៅបាន មិនមែនបង្ហាញលើបណ្តឹងសាទុក្ខទេ"[42]។

២៧. ហេតុនេះ សហមេធាវីនាំមុខសូមលើកឡើងថា សំណើលើកទីបួនមិនត្រឹមតែបកស្រាយខុសនូវបទដ្ឋានដែលត្រូវបានយកមកអនុវត្តដោយអង្គជំនុំជម្រះតុលាការកំពូលប៉ុណ្ណោះទេ តែសំណើនេះក៏មិនអាចលើកឡើងយ៉ាងសមហេតុផល ពីរបៀបដែលប្រតិចារិករបស់ ពេជ្រ ជឹម នឹងស្វែងរកការពិតបន្ថែមទៀត ដែលពាក់ព័ន្ធនឹងការធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ ដែលអង្គជំនុំជម្រះតុលាការកំពូលទទួលបាននោះទេ។

### ឃ. សំណើលើកទីបួនមិនជួយស្វែងរកការពិតទេ និងត្រូវចាត់ទុកដូចជាការបំបែកកិច្ចដំណើរការនីតិវិធីទៅវិញ

២៨. សហមេធាវីនាំមុខសូមលើកឡើងថា ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានទទួលភ័ស្តុតាង "ពាក់ព័ន្ធនឹងគោលនយោបាយក្នុងការកំណត់គោលដៅអ្នករដ្ឋការនៃរបបសាធារណរដ្ឋ កំណត់ត្រឹមតែការអនុវត្តនៅសហករណ៍នានានៅត្រាំកក់ ការដ្ឋានទំនប់ ១-មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់"[43] ដែលអង្គជំនុំជម្រះមានកាតព្វកិច្ចក្នុងការធ្វើសេចក្តី

---

[41] សាលដីកាក្នុង *រឿងក្តី Lubanga* កថាខណ្ឌ ៥៨ (ភាសាអង់គ្លេស)។

[42] សាលដីកាក្នុង *រឿងក្តី Lubanga* កថាខណ្ឌ ៥៧, ៥៩ (ភាសាអង់គ្លេស)។ យុត្តិសាស្ត្រនៅតុលាការ ICC និង អ.វ.ត.ក ស្របទៅនឹងវិសាលភាពដែលថា តុលាការទាំងពីរទទួលស្គាល់ថា តម្លៃនៃភ័ស្តុតាងគឺជាការទទួលខុសត្រូវចម្បងរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានស្តាប់សក្ខីកម្មលើភ័ស្តុតាងទាំងអស់។ *សូមមើលផងដែរ* សាលដីកាក្នុង *រឿងក្តី ឌុច* កថាខណ្ឌ ១៧ *សំអាងលើ* សាលដីកាក្នុង *រឿងក្តី Kupreškić* កថាខណ្ឌ ៣០ (ភាសាអង់គ្លេស)។

[43] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម កថាខណ្ឌ ៤៤។ ដូចបានកត់សម្គាល់ខាងលើ សហជនជាប់ចោទមិនត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម នូវបទឧក្រិដ្ឋស្តីពីការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុ

សន្និដ្ឋានជាថ្មីលើអង្គហេតុ និងអង្គច្បាប់ ដាច់ចេញពីការធ្វើសេចក្ដីសន្និដ្ឋាននានាដែលពាក់ព័ន្ធនឹងអត្ថិភាព និងការអនុវត្តគោលនយោបាយដែលបានលើកឡើង នៅក្នុងសំណុំរឿង ០០២/០១។ ហេតុនេះ សក្ខីកម្មរបស់ ពេជ្រ ជឹម ក្នុងសំណុំរឿង ០០២/០២ ត្រូវតែយកមកពិនិត្យ នៅក្នុងបរិបទនៃការចោទប្រកាន់ជាក់លាក់ដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលនៅក្នុងរឿងក្ដីនោះ។

សហមេធាវីនាំមុខសូមលើកឡើងថា ប្រសិនបើសក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង ០០២/០២ ត្រូវបានទទួលយកជាភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលទៅតាមសំណើនេះ សក្ខីកម្មនេះមិនជួយដល់ការស្វែងរកការពិតលើបណ្ដឹងសាទុក្ខទេ ដែលក្នុងករណីពិសេសនេះត្រូវតែយកមកវាយតម្លៃថាជាការបំបែកកិច្ចដំណើរការនីតិវិធីទៅវិញ។ សហមេធាវីនាំមុខសូមលើកឡើងថា ការទទួលយកប្រតិចារឹកពីការជំនុំជម្រះក្ដីដែលកំពុងដំណើរការ ដោយពុំមានការណែនាំពីបទចោទ បរិបទនៃសក្ខីកម្ម និងភ័ស្តុតាងផ្សេងទៀតដែលត្រូវបានស្ដាប់សក្ខីកម្មដោយអង្គជំនុំជម្រះសាលាដំបូងដដែលនោះ នឹងមិនមែនជាប្រយោជន៍យុត្តិធម៌ទេ។

ដោយពិចារណាពីកាលៈទេសៈពិសេសជុំវិញលក្ខណៈរបស់ផ្នែកនេះនៃភ័ស្តុតាង សហមេធាវីនាំមុខសូមលើកឡើងបន្ថែមថា ការទទួលយកសំណើលើកទីបួន និងសំណើផ្សេងៗទៀតដែលស្រដៀងគ្នានាពេលអនាគតនឹងមិនមែនជាការជម្រុញកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខបានឆាប់រហ័សនោះទេ។ វានឹងក្លាយជាការចាំបាច់សម្រាប់ភាគីផ្សេងៗគ្នា ក្នុងការស្នើសុំដាក់ភ័ស្តុតាងក្នុងបរិបទ និងលើអង្គសេចក្ដីឱ្យទទួលយកជាភ័ស្តុតាងបន្ថែម ដែលសម្រេចដល់ការធ្វើសេចក្ដីសន្និដ្ឋានលើអង្គហេតុ ដើម្បីជួយអង្គជំនុំជម្រះតុលាការកំពូលក្នុងការកំណត់ឱ្យបានត្រឹមត្រូវនូវភ័ស្តុតាងសរុបដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ សហមេធាវីនាំមុខសូមលើកឡើងថា ការអនុវត្តបែបនេះនឹងផ្ទុយពីភាពចាំបាច់នៃសវនាការដែលឆាប់រហ័ស និង តុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់ រួមទាំងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ[44]។

ហេតុនេះ សហមេធាវីនាំមុខសូមជំរុញឱ្យអង្គជំនុំជម្រះតុលាការកំពូលមេត្តាបដិសេធសំណើលើកទីបួន និងសូមធ្វើការពិចារណាទៅលើផ្នែក ឃ ដែលបានលើកឡើងខាងលើ នៅពេលសម្រេចទៅ

---

នយោបាយ ពាក់ព័ន្ធនឹងការសម្លាប់អ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅទួលពោធិ៍ជ្រៃទេ។ *សូមមើល* សាលក្រម កថាខណ្ឌ ៨១២។

[44] វិធានផ្ទៃក្នុង វិធាន ១២*ស្ទួនពីរ* (១)។

លើសំណើស្រដៀងគ្នាដែលអាចមាននាពេលអនាគត។

**សំណើ**

**អាស្រ័យហេតុនេះ** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

(១) **បដិសេធ** សំណើលើកទីបួនរបស់ នួន ជា។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលយកចម្លើយតបនេះដោយគោរព។

| កាលបរិច្ឆេទ | នាម | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥ | **Marie GUIRAUD** សហមេធាវីអន្តរជាតិនាំមុខ | ភ្នំពេញ | |